**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៩០ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និង ការប្រព្រឹត្តទៅ នៃមូលនិធិធានាឥណទាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃមូលនិធិធានាឥណទាន ។

**មាត្រា ២.- គោលដៅ**

អនុក្រឹត្យនេះ មានគោលដៅកំណត់ក្របខ័ណ្ឌគតិយុត្តក្នុងការផ្តល់ការធានាលើកម្ចីដែលផ្តល់ដោយធនាគារពាណិជ្ជ ដល់រោងម៉ាស៊ីនកិនស្រូវ ចំពោះសកម្មភាពការប្រមូលទិញស្រូវ សម្រាប់កែច្នៃ ដើម្បីនាំចេញ និងដល់សហគមន៍អង្គការកសិករ ក្នុងការប្រមូលទិញស្រូវ ឬ ស្តុកស្រូវ ស្របតាមឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.- វិសាលភាព**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិធានាឥណទាន ដែលជាកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញការផ្តល់កម្ចីដោយធនាគារពាណិជ្ជ តាមរយៈការផ្តល់ការធានា ចំពោះសកម្មភាពជាអាទិភាពជាដំណាក់កាល ដូចតទៅ÷

- ដំណាក់កាលទី១: ការធានាលើកម្ចីដែលផ្តល់ដោយធនាគារពាណិជ្ជ ចំពោះរោងម៉ាស៊ីនកិនស្រូវ ក្នុងការប្រមូលទិញស្រូវ សម្រាប់ការកែច្នៃ ដើម្បីនាំចេញ ។
- ដំណាក់កាលទី២: ពង្រីកការធានាលើកម្ចីដែលផ្តល់ដោយធនាគារពាណិជ្ជ និង/ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដល់សហគមន៍អង្គការកសិករ ក្នុងការប្រមូលទិញស្រូវ ឬ ស្តុកស្រូវ ។

## ជំពូកទី ២

## រចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា ៤.- គណៈកម្មាធិការដឹកនាំការងារគម្រោងមូលនិធិធានាឥណទាន**

មូលនិធិធានាឥណទាន ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មាធិការដឹកនាំការងារគម្រោងមូលនិធិធានាឥណទានមួយដែលមានតួនាទីកំណត់គោលនយោបាយក្នុងការប្រើប្រាស់មូលនិធិធានាឥណទាន ស្របតាមឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល និងឯកសារគម្រោងមូលនិធិធានាឥណទាន។

សមាសភាពគណៈកម្មាធិការដឹកនាំការងារគម្រោងមូលនិធិធានាឥណទាន មានដូចខាងក្រោម÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង | ប្រធាន |
| ២- ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬ តំណាង | អនុប្រធាន |
| ៣- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០១ រូប | សមាជិក |
| ៤- តំណាងធនាគារជាតិនៃកម្ពុជា ចំនួន ០១ រូប | សមាជិក |
| ៥- ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | លេខាធិការ |

ការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈកម្មាធិការដឹកនាំការងារគម្រោងមូលនិធិធានាឥណទាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រធានគណៈកម្មាធិការដឹកនាំការងារគម្រោងមូលនិធិធានាឥណទាន មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នផ្សេងទៀតចូលរួមក្នុងការពិភាក្សារបស់ខ្លួន ក្នុងករណីចាំបាច់ ។

**មាត្រា ៥.- អង្គភាពអនុវត្ត**

អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន ដែលត្រូវបានបង្កើតឡើងតាមរយៈប្រកាសលេខ ១០៤០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអង្គភាពអនុវត្តគម្រោងមូលនិធិធានាឥណទាន ។

## ជំពូកទី ៣

## ប្រភពធនធាន និងកម្រៃធានាឥណទាន

**មាត្រា ៦.- ប្រភពធនធាន**

ប្រភពធនធាននៃមូលនិធិធានាឥណទាន រួមមាន ÷

- ធនធានដំបូងជាឥណទានពិសេសចំនួន ១០៥.០០០.០០០.០០០ រៀល (មួយរយប្រាំពាន់លានរៀល) ដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- ធនធានបន្ថែមពីប្រភពថវិកាជាតិ ទៅតាមការចាំបាច់របស់រាជរដ្ឋាភិបាល
- ការចូលរួមវិភាគទានពីដៃគូអភិវឌ្ឍន៍ និង
- ប្រភពផ្សេងទៀត ។

**មាត្រា ៧.- កម្រៃធានាឥណទាន**

កម្រៃធានាឥណទាន ត្រូវមានលក្ខណៈសមរម្យ ដើម្បីរក្សាភាពទាក់ទាញការចូលរួមរបស់ធនាគារពាណិជ្ជក្នុងគម្រោងមូលនិធិធានាឥណទាន ។

កម្រៃធានាឥណទាននេះ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

កម្រៃធានាឥណទានដែលទទួលបានមកពីការផ្តល់ការធានាលើកម្ចីដោយធនាគារពាណិជ្ជនេះ ត្រូវយកទៅប្រើប្រាស់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការនៃគម្រោងមូលនិធិធានាឥណទាន និងការបង្កើនមូលនិធិធានាឥណទាន តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## ទោសប្បញ្ញត្តិ

**មាត្រា ៨.- ទោសប្បញ្ញត្តិ**

មន្ត្រីសាធារណៈទាំងឡាយ ដែលត្រូវបានរកឃើញថា មិនបានគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដោយការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ក្នុងការគ្រប់គ្រង ឬ ការប្រើប្រាស់មូលនិធិក្នុងស្ថានភាពមិនសមស្រប និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយ តាមរយៈការលួចកិបកេង ក្លែងបន្លំ ឬប្រើប្រាស់មូលនិធិនេះ ខុសគោលដៅ ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។/

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៩.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១០*
- *រាជកិច្ច*